# វត្តមានថ្នាក់ដឹកនាំជាន់ខ្ពស់របស់អាមេរិក និងការពង្រីកខ្លួនយ៉ាងលឿនរបស់ចិន នៅអាស៊ី

ដោយ៖ លោក អ៊ុច លាង អ្នកសិក្សាស្រាវជ្រាវនៃនាយកដ្ឋានសិក្សាអាស៊ី អាហ្វ្រិក និងមជ្ឈិមបូព៌ា
នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា នៃរាជបណ្ឌិត្យសភាកម្ពុជា

នៅក្នុងអំឡុងរដ្ឋបាលរបស់អតីតប្រធានាធិបតី Donal Trump អាស៊ាន មិនត្រូវបានសហរដ្ឋអាម៉េរិកយកចិត្តទុកដាក់នោះទេ គឺហាក់នៅឆ្ងាយពីអាម៉េរិក ដោយរដ្ឋបាលនេះ ពុំសូវលើកតម្លៃដល់បណ្តាប្រទេសនៅតំបន់ស៊ានច្រើននោះទេ គឺគិតតែពីផលប្រយោជន៍របស់ប្រជាជាតិខ្លួនឯង (American First)។ តែរហូតជិតដល់ចប់អាណត្តិ រដ្ឋបាលលោក Trump ទើបចាប់ផ្តើមយកចិត្តទុកដាក់ ទាំងការពង្រឹងកម្លាំងសម្ព័ន្ធមិត្ត និងវិស័យសន្តិសុខតំបន់ ដែលខណៈប្រទេសមហាយក្សចិន បានពង្រីកខ្លួនកាន់តែធំឡើងៗ និងគ្របដណ្តប់ស្ទើតែទូទាំងអាស៊ានទៅហើយ។ រហូតមកដល់រដ្ឋាបាន លោក Joe Biden ទើបបានចាប់ផ្តើមបើកភ្នែកសម្លឹងមើលអាស៊ាន ជាសំខាន់ ដោយការប្តូរយុទ្ធសាស្ត្រ ដើម្បីប្រមូលផ្តុំកម្លាំងសម្ព័ន្ធមិត្តឡើងវិញ ដើម្បីទប់ស្កាត់ ការកើនឡើងនៃឥទ្ធិពលរបស់ចិន។ រដ្ឋបាល លោក Biden បានបញ្ជូនថ្នាក់ដឹកនាំកំពូលៗរបស់ខ្លួន មកបំពេញទស្សនកិច្ចនៅតំបន់អាស៊ី ក្រោមរបៀបវារៈតែមួយប៉ុណ្ណោះ គឺ «***កៀងគរកម្លាំងសម្ពន្ធមិត្តដើម្បីរាំងខ្ទប់ឥទ្ធិពលរបស់ចិនក្នុងតំបន់***» ។ កាលពីខែកក្កដា ឆ្នាំ២០២១ កន្លងទៅ រដ្ឋបាលលោក Biden បានបញ្ជូនរដ្ឋមន្ត្រីការពារជាតិ លោក Lloyd Austin មកកាប់តំបន់ អាស៊ាន គឺទៅកាន់ប្រទេសសិង្ហបុរី វៀតណាម និងហ្វីលីពីន និងថ្មីៗនេះ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២១ លោកស្រី Kamala Harris អនុប្រធានាធិបតីអាម៉េរិក ធ្វើដំណើរទស្សនកិច្ច ទៅកាន់ប្រទេសដែលសហរដ្ឋអាម៉េរិក ចាត់ទុកថាជាគន្លឹះដើម្បីទប់ទល់នឹងការពង្រីកខ្លួនកាន់តែលឿន របស់ប្រទេសចិននៅក្នុងតំបន់ គឺប្រទេសសិង្ហបុរី និងវៀតណាម ក្រោយពេលប្រទេសហ្វីលីពីនបានប្រកាសប្តូរជំហរ ដោយសម្រេចដកយកមកវិញ លិខិតបញ្ចប់កិច្ចព្រមព្រៀងស្តីពីវត្តមានទ័ពអាមេរិកនៅហ្វីលីពីន កាលពីខែ កុម្ភៈឆ្នាំ២០២០កន្លងទៅ ក្នុងអំឡុងពេលដំណើរទស្សនកិច្ច របស់រដ្ឋមន្ត្រីការពារជាតិ អាម៉េរិក លោក Lloyd Austin នៅហ្វីលីពីន។ ចំណែកលោករដ្ឋមន្ត្រីការបរទេសអាម៉េរិក Antony Blinken បានផ្តើមបំពេញដំណើរទស្សនកិច្ចនៅឥណ្ឌា កាលពីថ្ងៃអង្គារ ទី២៧ ខែកក្កដា។ ចំណែកឯអនុរដ្ឋមន្ត្រីការបរទេស Wendy Sherman ក៏បានទៅជួបប្រមុខការទូតចិននៅក្នុងប្រទេសចិន ទី២៥-២៦ ខែកក្កដា។

ដំណើរទស្សនកិច្ចនៅតំបន់អាស៊ីរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ របស់អាម៉េរិក មកតំបន់អាស៊ី ជាការឆ្លុះបញ្ចាំង ពីការបង្កើនល្បឿននៃកិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសនៅអាស៊ីអាគ្នេយ៍ ក្នុងគោលដៅដើម្បីទប់ទល់នឹងឥទ្ធិពលរបស់ចិន ក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក ក្រោយពីបានធ្លាក់ចុះខ្លាំង ក្នុងអាណត្តិរដ្ឋបាល របស់លោក Trump ដែលបានចាប់យកតំបន់មជ្ឈិមបូព៌ាខ្លាំងជាងតំបន់អាស៊ីអាគ្នេយ៍។

ក្រោមការដឹកនាំរបស់រដ្ឋបាល លោក Joe Biden កំពុងព្យាយាមស្តារទំនាក់ទំនងល្អជាមួយបណ្តាប្រទេសនានា នៅក្នុងតំបន់អាស៊ីឡើងវិញ ដោយមានចេតនាចង់ ធានាអះអាងថាអាម៉េរិក មានសមត្ថភាពផ្តល់ស្ថិរភាពដល់តំបន់ដែលចិនកំពុងពង្រីកឥទ្ធិពល កាន់តែខ្លាំងឡើងៗ ជាក់ស្តែងគឺតំបន់អាស៊ីអាគ្នេយ៍ និងជាងនេះទៅទៀតគឺសេដ្ឋកិច្ចនៅតំបន់អាស៊ី ដែលអាចជួយឱ្យប្រទេសចិន នឹងក្លាយជាមហាអំណាចសេដ្ឋកិច្ចពិភពលោកនាពេលខាងមុខ។

ប្រសិនបើយើងនៅមិនទាន់ភ្លេច ឃ្លាថា «សតវត្សរ៍ទី២១ជាសតវត្សរ៍អាស៊ី» នោះយើងពិតជានឹងគិតទៅដល់ ថាហេតុអ្វីបានជាសហរដ្ឋអាម៉េរិក សម្រេចកដកងទ័ពចេញពីអាហ្វហ្គានីស្ថាន បន្ថយភាពតានតឹងនៅមជ្ឈិមបូព៌ា។

សូមរំលឹកថា បើយោងតាមទស្សនៈព្រឹត្តិការណ៍ពិភពលោក របស់វិទ្យុបារាំងអន្តរជាតិ សតវត្សរ៍ទី២១ជាសតវសតវត្សរ៍អាស៊ី ឬ The Asian Century គឺជាឃ្លាមួយដើម្បីសម្គាល់ដល់ការព្យាករណ៍ពី ឥទ្ធិពលគ្រប់ដណ្តប់នៃអំណាចនយោបាយ និងវប្បធម៌អាស៊ី នៅសតវត្សរ៍ទី២១ ដោយគេសន្មតតាមនិន្នាការប្រជាសាស្ត្រ និងសេដ្ឋកិច្ច នាពេលអនាគត។ គោលគំនិតនេះស្រដៀងទៅនឹងលក្ខណៈនៃសតវត្សរ៍ទី១៨របស់មហាអំណាចចក្រភពបារាំង សតវត្សរ៍ទី១៩ របស់មហាអំណាចចក្រភពអង់គ្លេស និងសតវត្សរ៍ទី២០ ដែលជាសតវត្សរ៍របស់សហរដ្ឋអាមេរិក។ ទោះជាយ៉ាងណា បើមើលតាមប្រវត្តិសាស្ត្ររាប់ពាន់ឆ្នាំ ពោលគឺតាំងពីឆ្នាំទី១ ដល់ឆ្នាំទី១៨០០ អាស៊ីតែងតែជាតំបន់នៃអំណាចសេដ្ឋកិច្ច និងនយោបាយការទូត ព្រោះថាចិន និងឥណ្ឌា ជាប្រទេសដែលមានទំហំសេដ្ឋកិច្ចធំបំផុតតាំងពីដើមរៀងមក លើកលែងតែនៅអំឡុងទសវត្សរ៍ទី១៨ដែលសេដ្ឋកិច្ចបស្ចិមប្រថទេសកើនឡើងជាងគេក្រោយបដិវត្តន៍ឧស្សាហកម្ម។

ផ្អែកលើរបាយការណ៍ចេញផ្សាយដោយ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងធនាគារពិភពលោក ប្រជាជនអាស៊ីចំនួន៣ពាន់លាននាក់ អាចបង្កើនកម្រិតជីវភាពរបស់ខ្លួនប្រហាក់ប្រហែលទៅនឹងប្រជាជនអឺរ៉ុបនាពេលបច្ចុប្បន្ន ស្របពេលដែលតំបន់អាស៊ីអាចនឹងមានទំហំសេដ្ឋកិច្ចជាងពាក់កណ្តាលនៃសេដ្ឋកិច្ចសកលនៅពាក់កណ្តាលសតវត្សរ៍ទី២១។

តើឃ្លា សតវត្សរ៍អាស៊ី មានប្រភពដើមពីណា? នៅឆ្នាំ១៩២៤ លោក Karl Haushofer ឧត្តមសេនីយ៍ សាស្ត្រាចារ្យ ភូមិសាស្ត្រវិទូ និងអ្នកនយោបាយអាឡឺម៉ង់ បានប្រើពាក្យ “យុគសម័យប៉ាស៊ីហ្វិក ឬ Pacific age” ដោយបានមើលឃើញពីការរីកចម្រើនលូតលាស់របស់ប្រទេសជប៉ុន ចិននិងឥណ្ឌា។ គាត់បានប្រមើលឃើញអំពីការកើនឡើងនៃតំបន់ប៉ាស៊ីហ្វិក ក្រោយយុគសម័យអាត្លង់ទិករបស់អាមេរិក និងយុគសម័យមេឌីទែរ៉ាណេរបស់អឺរ៉ុប។

ជាការពិត ឃ្លា សតវត្សរ៍អាស៊ី ត្រូវបានគេលើកឡើងមកនិយាយ តាំងពីនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០។ វាជាអំឡុងពេលនៃការប្រជុំរវាងមេដឹកនាំសាធារណរដ្ឋប្រជាមានិតចិន លោក Deng Xiaoping និងនាយករដ្ឋមន្ត្រីឥណ្ឌា Rajiv Gandhi ។ ក៏ប៉ុន្តែ កាលនោះ លោក Deng

Xi aopi ng បានលើកឡើងថា៖ “*ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ មានគេបាននិយាយថា សតវត្សរ៍បន្ទាប់ជាសតវត្សរ៍អាស៊ី និងប៉ាស៊ីហ្វិក ហើយប្រសិនបើវានឹងកើតឡើងមែន ខ្ញុំមិនយល់ស្របនឹងទស្សនៈនេះទេ*”។

នៅតំបន់អាស៊ីបច្ចុប្បន្ន កំណើនប្រជាជនត្រូវបានគេរំពឹងថានឹងបន្តកើនឡើងបន្ថែមទៀត យ៉ាងហោចណាស់នៅពាក់កណ្តាលសតវត្សរ៍ទី២១ ទោះបីជាអត្រាកំណើនមានការធ្លាក់ចុះ ចាប់តាំងពីចុងសតវត្សរ៍ទី២០ក៏ដោយ។ បច្ចុប្បន្ន អាស៊ីមានប្រជាជនចំនួនជាង ៤ពាន់លាននាក់។ ប្រជាជនអាស៊ីនឹងអាចមានចំនួនច្រើនជាង ៥ពាន់លាននាក់ នៅឆ្នាំ២០៥០។ ក្នុងពេលជាមួយគ្នានេះ ចំនួនប្រជាជនអាម៉េរិកខាងជើង និងអឺរ៉ុបប្រៀបធៀបជាមួយប្រជាជនសរុបលើពិភពលោក ត្រូវបានគេរំពឹងថានឹងធ្លាក់ចុះខ្លាំងនៅថ្ងៃខាងមុខ។

សម្រាប់កំណើនសេដ្ឋកិច្ច អត្រាកំណើនសេដ្ឋកិច្ចរំពឹងទុករបស់ចិន និងប្រទេសជិតខាងអាស៊ីផ្សេងទៀត នឹងបង្កើតលក្ខខណ្ឌសមស្របផ្សេងៗ ដើម្បីអនុញ្ញាតឱ្យសេដ្ឋកិច្ចរបស់ខ្លួនកាន់តែខិតជិត តាមទាន់បណ្តាប្រទេសបស្ចិមលោក។ អំណាចសេដ្ឋកិច្ចជាប្រភពយ៉ាងចម្បងសម្រាប់អំណាចយោធា។ ក្នុងរយៈពេល៣០ឆ្នាំខាងមុខ គេអាចរំពឹងដល់កំណើនប្រាក់ចំណូលរបស់ប្រជាជនអាស៊ីម្នាក់ៗ តួយ៉ាងប្រជាជនចិន ឥណ្ឌា ឥណ្ឌូនេស៊ី ហ្វីលីពីន វៀតណាម និងម៉ាឡេស៊ី ដែលជាក្រុមប្រទេសមានប្រជាជនច្រើន។ ជាការពិត ទោះជាកម្រិតជីវភាពរបស់ប្រជាជនអាស៊ីមិនអាចតាមទាន់កម្រិតជីវភាពប្រជាជនអឺរ៉ុប ក៏ទំហំសេដ្ឋកិច្ចអាស៊ីត្រូវគេរំពឹងថាអាចជិតជាងពាក់កណ្តាលនៃសេដ្ឋកិច្ចសកល។ ជាក់ស្តែង អំឡុងសង្គ្រាមត្រជាក់ សេដ្ឋកិច្ចអឺរ៉ុប និងអាមេរិកខាងជើងបូកបញ្ចូលគ្នាជិតពាក់កណ្តាលនៃសេដ្ឋកិច្ចសកល នាអំឡុងពេលនោះ។

ក្នុងវិស័យផ្សេងៗ រួមមាន ការកើនឡើងវិស័យបច្ចេកវិទ្យា ហិរញ្ញវត្ថុ និងវប្បធម៌អាស៊ីជាដើម ក៏ត្រូវបានគេសិក្សាថាអាចឥទ្ធិពលយ៉ាងខ្លាំងលើមនុស្សជំនាន់ក្រោយៗរបស់ពិភពលោក។

មួយវិញទៀតក្រោមរដ្ឋបាលរបស់លោក Trump ក៏បានបង្កើតយុទ្ធសាស្ត្រ “ឥណ្ឌូប៉ាស៊ីហ្វិក-Indo-Pacific” ឡើង គឺដើម្បី ទប់ទល់នឹងការពង្រីកឥទ្ធិពលរបស់ចិននៅក្នុងតំបន់ ហើយយុទ្ធសាស្ត្រទប់ទល់នឹងឥទ្ធិពលរបស់ចិននេះ ត្រូវគេរៀបចំធ្វើឡើង តាមរយៈការរួមកម្លាំងគ្នា រវាងប្រទេសចំនួន ៤ គឺ អាមេរិក ជប៉ុន អូស្ត្រាលី និងឥណ្ឌា បង្កើតទៅជាបក្សសម្ព័ន្ធប្រឆាំងចិន នៅក្នុងតំបន់ “ឥណ្ឌូប៉ាស៊ីហ្វិក” ដើម្បីប្រកួតប្រជែងនឹងគម្រោង BRI របស់ចិន។

សូមរំលឹកផងដែរថា បើយោងតាមទស្សនៈព្រឹត្តិការណ៍ពិភពលោក របស់វិទ្យុបារាំងអន្តរជាតិ យុទ្ធសាស្ត្រ “ឥណ្ឌូប៉ាស៊ីហ្វិក” បើគិតទៅតាមទីតាំងភូមិសាស្ត្រសុទ្ធសាធ គឺមិនមានអ្វីខុសប្លែកគ្នាពី “អាស៊ីប៉ាស៊ីហ្វិក” នោះទេ ក៏ប៉ុន្តែ ក្នុងពេលជាមួយគ្នា “ឥណ្ឌូប៉ាស៊ីហ្វិក” ក៏មិនមែនគ្រាន់តែជាឈ្មោះថ្មី ដែលគេប្រើជំនួស “អាស៊ីប៉ាស៊ីហ្វិក” នោះដែរ។ ការណ៍ដែលគេនាំគ្នាប្រើពាក្យ “ឥណ្ឌូប៉ាស៊ីហ្វិក” ជំនួសឱ្យ "អាស៊ីប៉ាស៊ីហ្វិក" នៅក្នុងពេលបច្ចុប្បន្ននេះ គឺមានអត្ថន័យខាងភូមិសាស្ត្រនយោបាយ ដែលគូសបញ្ជាក់ពីការផ្លាស់ប្តូរ ឬដំណើរវិវឌ្ឍនៃយុទ្ធសាស្ត្ររបស់ប្រទេសមហាអំណាច នៅក្នុងតំបន់នេះ។ ដំណើរវិវឌ្ឍនៃយុទ្ធសាស្ត្រពី “អាស៊ីប៉ាស៊ីហ្វិក” ទៅ “ឥណ្ឌូប៉ាស៊ីហ្វិក” គឺផ្តោតទៅលើចំណុចសំខាន់ចំនួនពីរ។

ទីមួយ គឺការបង្កើនចំណាប់អារម្មណ៍កាន់តែសំខាន់ទៅលើឥណ្ឌា និងមហាសមុទ្រឥណ្ឌា ដែលត្រូវបានគេមើលឃើញថា ជាតំបន់ដ៏សំខាន់ និងដ៏មានសក្តានុពល ទាំងខាងផ្នែកសេដ្ឋកិច្ច និងខាងផ្នែកសន្តិសុខ។

ឥណ្ឌា ក្រៅពីជាប្រទេសដែលមានប្រជាជនច្រើនជាងគេលំដាប់ទីពីរបន្ទាប់ពីចិន ក៏ជាប្រទេសដែលមានសេដ្ឋកិច្ចរីកលូតលាស់យ៉ាងលឿនផងដែរ នៅក្នុងពេលបច្ចុប្បន្ននេះ។ អ្នកសេដ្ឋកិច្ចជាទូទៅបាននាំគ្នាធ្វើការព្យាករថា នៅឆ្នាំ២០៣០ខាងមុខនេះ ឥណ្ឌានឹងប្រជែងឈ្នះសហរដ្ឋអាមេរិក ក្លាយជាមហាអំណាចសេដ្ឋកិច្ចពិភពលោកលំដាប់ទីពីរ នៅពីក្រោយចិន ដែលនឹងក្លាយជាមហាអំណាចសេដ្ឋកិច្ចពិភពលោកលំដាប់ទីមួយ។

មហាសមុទ្រឥណ្ឌាវិញក៏ជាតំបន់យុទ្ធសាស្ត្រដ៏សំខាន់មួយផងដែរ។ ក្រៅពីជាតំបន់ដែលសម្បូរធនធានធម្មជាតិ មហាសមុទ្រឥណ្ឌាមានទីតាំងជាយុទ្ធសាស្ត្រដ៏សំខាន់មួយ ដោយស្ថិតនៅជាចំណុចកណ្តាល ភ្ជាប់តំបន់យុទ្ធសាស្ត្រធំៗទាំងបី គឺអឺរ៉ុប មជ្ឈិមបូព៌ា និងអាស៊ី, ជាលំហសមុទ្រដ៏សំខាន់ សម្រាប់ការដឹកជញ្ជូនតាមសមុទ្រ ដែលជាសរសៃឈាមនៃសេដ្ឋកិច្ចពិភពលោក ហើយជាពិសេស មហាសមុទ្រឥណ្ឌា គឺជាច្រកឆ្លងកាត់ដែលមិនអាចចៀសរួច ក្នុងការដឹកជញ្ជូនធនធានធម្មជាតិ (ជាពិសេសប្រេង) ពីអាហ្វ្រិក និងមជ្ឈិមបូព៌ា មកកាន់ប្រទេសឥណ្ឌា និងចិន។

ចំណុចសំខាន់ទីពីរ នៃយុទ្ធសាស្ត្រ "ឥណ្ឌូប៉ាស៊ីហ្វិក" គឺការទប់ទល់នឹងការពង្រីកឥទ្ធិពលចិននៅក្នុងតំបន់ ហើយយុទ្ធសាស្ត្រទប់ទល់នឹងឥទ្ធិពលរបស់ចិននេះត្រូវគេរៀបចំធ្វើឡើង តាមរយៈការរួមកម្លាំងគ្នា រវាងប្រទេសចំនួន ៤ គឺ អាមេរិក ជប៉ុន អូស្ត្រាលី និងឥណ្ឌា បង្កើតទៅជាបក្សសម្ព័ន្ធប្រឆាំងចិន នៅក្នុងតំបន់ "ឥណ្ឌូប៉ាស៊ីហ្វិក"។ ហេតុដូច្នេះហើយបានជាគេសង្កេតឃើញថា ជាទូទៅ ប្រទេសទាំង ៤នេះហើយ ដែលតែងតែប្រើពាក្យ "ឥណ្ឌូប៉ាស៊ីហ្វិក" ញឹកញាប់ជាងគេ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

"ឥណ្ឌូប៉ាស៊ីហ្វិក"នេះ ត្រូវបានសហរដ្ឋអាមេរិកកំណត់ជាយុទ្ធសាស្ត្រជាផ្លូវការ កាលពីខែវិច្ឆិកា ឆ្នាំ ២០១៧កន្លងទៅ តាមរយៈសុន្ទរកថារបស់លោកដូណាល់ ត្រាំ នៅដាណាង ប្រទេសវៀតណាម ក្នុងឱកាសជំនួបកំពូលនៃវេទិកាសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិក ហៅកាត់ថា APEC។ នៅពេលនោះ លោកដូណាល់ ត្រាំ បានហៅយុទ្ធសាស្ត្រថ្មីនេះថាជាយុទ្ធសាស្ត្រ "ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ" (Free and Open Indo-Pacific)។

យុទ្ធសាស្ត្រ "ឥណ្ឌូប៉ាស៊ីហ្វិក" នេះ ក៏ត្រូវបានបារាំងកំណត់ជាផ្លូវការ ដាក់ចូលទៅក្នុងនយោបាយការពារជាតិរបស់ខ្លួនដែរ កាលពីខែមិថុនា ឆ្នាំ២០១៨កន្លងទៅ។ សម្រាប់បារាំង តំបន់ឥណ្ឌូប៉ាស៊ីហ្វិករឹតតែមានសារៈសំខាន់ទៅទៀត ដោយសារថា បារាំង ថ្វីដ្បិតតែមានទីតាំងស្ថិតនៅអឺរ៉ុប ក៏ប៉ុន្តែ មានដែនដីជាច្រើន ដែលជាកោះ ឬប្រជុំកោះ ទាំងនៅក្នុងមហាសមុទ្រឥណ្ឌា និងមហាសមុទ្រប៉ាស៊ីហ្វិក។ បារាំង គឺជាប្រទេសដែលមានតំបន់សេដ្ឋកិច្ចផ្តាច់មុខលាតសន្ធឹងលើផ្ទៃសមុទ្រច្រើនជាងគេលំដាប់ទីមួយនៅលើពិភពលោក ហើយក្នុងចំណោមតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់បារាំងទាំងជាង ៩លានគីឡូម៉ែត្រក្រឡា មានរហូតដល់ទៅជាង ៩០% ស្ថិតនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។

ដូច្នេះវត្តមានរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់សហរដ្ឋអាមេរិកនៅតំបន់អាស៊ី ពិសេសនៅតំបន់អាស៊ាន នាពេលនេះ គឺសហរដ្ឋអាមេរិក ព្យាយាមទប់ស្កាត់ការកើនឡើងយ៉ាងខ្លាំង នៃឥទ្ធិពលរបស់ប្រទេសចិនក្នុងតំបន់ ក៏ដូចជាកៀងគរប្រទេសជាសម្ព័ន្ធមិត្ត ដែលសហរដ្ឋអាមេរិក ចាត់ទុកថាជាប្រទេសគន្លឹះ ដើម្បីរួមគ្នា ទប់ទល់នឹងការពង្រីកខ្លួនកាន់តែលឿន របស់ប្រទេសចិននៅក្នុងតំបន់អាស៊ី ដើម្បីឈានទៅក្លាយជា មហាអំណាចសេដ្ឋកិច្ចពិភពលោកនាពេលខាងមុខ៕